

# មហារីកប្រមោយដៃស្បូន

## អាចហៅថាមហារីកនៃប្រមោយដៃស្បូន

## អ្វីទៅដែលស្ត្រីត្រូវតែដឹង

### អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

រោគមហារីក ប្រមោយដៃស្បូនពិបាករកឃើញណាស់។ វាអាចកើតដោយគ្មានរោគសញ្ញាសោះរហូតដល់មហារីកនេះវារាលដាលតែម្តង។ អ្វីៗដែលអ្នកមានអារម្មណ៍ ឬក៏ឃើញប្លែកនៅលើខ្លួនអ្នក វាហាក់ដូចជាមិនមានអ្វី ទាក់ទងនឹងរោគមហារីកសោះ។ រោគសញ្ញាខាងក្រោមមិនមានន័យថាវាអាចបង្កើតរោគមហារីកទេ ក៏ប៉ុន្តែអ្នកគួរតែនិយាយប្រាប់រោគសញ្ញាទាំងនោះទៅវេជ្ជបណ្ឌិតជាបន្ទាន់៖

- មានអារម្មណ៍ណែនឬក៏ហើមនៅក្នុងពោះដោយសារមានទឹកលើសចំនួន។ ហើមនេះ មានលក្ខណៈខុសផ្លែកពីមករដូវរាល់ខែ។
- ឡើងឬស្រក់ទម្ងន់ដោយឥតមូលហេតុ។
- ឡើងធំជាងមុននៅកន្លែងក្រពះ។
- ធ្លាក់ឈាមឬក៏ ធ្លាក់សពីរន្ធយោនី (ដែលខុសផ្លែកពីមករដូវតាមធម្មតា)
- មានបញ្ហាក្រពះមិនចេះស្រាកស្រាណ។ អ្នកមានការឈឺចុកចាប់ខ្យល់ក្នុងពោះឬក៏ ចង់ក្អួត។
- ឈឺខ្នងឬឈឺជើង៕

### តើអ្វីទៀតដែលធ្វើឲ្យជំងឺនេះកាន់តែមានគ្រោះថ្នាក់ថែម?

អ្វីដែលបណ្តាលឲ្យមានគ្រោះថ្នាក់ក្នុងជំងឺមហារីកប្រមោយដៃស្បូន មានដូចតទៅ៖

- មានអាយុលើសពី៥០ឆ្នាំ។
- អ្នកមានមករដូវលើកដំបូងនៅវ័យក្មេង (មុននឹងអាយុ១២ឆ្នាំ)។
- មិនធ្លាប់មានផ្ទៃពោះ ឬក៏សំរាលកូន។
- សំរាលកូនដំបូងបន្ទាប់ពីមានអាយុលើសពី៣០ឆ្នាំ។
- ពិសារបារី។
- មិនមានផ្ទៃពោះ។
- មានជំងឺមហារីកដោះ ក្នុងពេលបច្ចុប្បន្ននេះ ឬក៏កាលពីមុនមក។
- មានសមាជិកណាមួយនៅក្នុងក្រុមគ្រួសារ ធ្លាប់មានជំងឺមហារីកដោះ មហារីកនៅចុងពោះវៀន ឬក៏មហារីកប្រមោយដៃស្បូន។
- មានទំងន់ធំធាត់ខ្លាំងពេក។
- បានប្រើការព្យាបាលជាយូរពេល នឹងអ័រម៉ូនជាជំនួយនៃកោសិកាណាមួយក្នុងខ្លួនហៅ អែស៍ត្រូយឺន។ការព្យាបាលតាមរបៀបអែស៍ត្រូយឺន ឬក៏តាមរបៀបអ័រម៉ូន។

### តើខ្ញុំអាចធ្វើដូចម្តេចទៅ ដើម្បីជួយរកឲ្យឃើញរោគមហារីកប្រមោយដៃស្បូន ឲ្យបានទាន់ពេល ?

- ស្ត្រីដែលមានការរួមដំណេក ឬក៏ស្ត្រីដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវតែទៅពិនិត្យស្បូន (ធ្វើផាប់តេស៍)ជារៀងរាល់ឆ្នាំ។
- ពេលពិនិត្យស្បូនវេជ្ជបណ្ឌិតនឹងស្ទាបសរីរាង្គរបស់ស្ត្រីភេទ

  ពិនិត្យមើលទំហំនិងរាងរៅ
  ប៉ុន្តែមហារីកប្រមោយដៃស្បូនភាគច្រើនពិបាករកឲ្យឃើញមុនពេលណាស់។ មានការពិបាកពីព្រោះប្រមោយដៃស្បូននៅកប់ជ្រៅពេកក្នុងខ្លួន ហើយវេជ្ជបណ្ឌិតមិនអាចស្ទាបឃើញដោយស្រួលៗទេ។ ការពិនិត្យស្បូន(ធ្វើផាប់តេស៍)អាចឲ្យជួយរកឃើញមហារីកកស្បូនមុន

  តែការពិនិត្យស្បូននេះមិនអាច ជួយឲ្យរកឃើញមហារីកប្រមោយដៃស្បូនមុនបានឡើយ។
- មានការពិនិត្យផ្សេងៗទៀតដែលអាចជួយរករោគមហារីកប្រមោយដៃស្បូននេះ តែជួនកាលវាមិនអាចរកឃើញឲ្យបានមុនពេលទេ។ អ្នកហើយនិងវេជ្ជបណ្ឌិតរបស់អ្នកពិភាក្សារគ្នាអំពីការពិនិត្យដែលល្អប្រសើរចំពោះអ្នក។ តែត្រូវជាការយោកយល់ទៅតាមអាយុនឹងប្រវត្តិសុខភាពរបស់អ្នក។

  ការខុសផ្លែកដែលអ្នកបានកត់សំគាល់អំពីខ្លួនអ្នក។

  ការពិនិត្យគឺរួមទាំងពិនិត្យឈាមផ្សេងៗ និងឆ្លុះអុលត្រាសោនដោយមិនមានការឈឺចុកចាប់។

តទំព័រខាងក្រោយ

